# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១១៣

## ស្តីពី

## ការទទួលស្គាល់កាកបាទក្រហមកម្ពុជា

### យើង

### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

### ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៣៧៨/នស ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ១៩៥៨ ស្តីពីការទទួលស្គាល់សមាគមជាតិកាកបាទក្រហមកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

### ត្រាស់បង្គាប់

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

មាត្រា ១ ---

ព្រះរាជក្រឹត្យនេះទទួលស្គាល់ កាកបាទក្រហមកម្ពុជា ជាសមាគមស្ម័គ្រចិត្តផ្តល់ជំនួយ និងពីនេះតទៅត្រូវបានទទួលស្គាល់ជា " **កាកបាទក្រហមកម្ពុជា** " ។

មាត្រា ២ .—

កាកបាទក្រហមកម្ពុជា បច្ចុប្បន្នជាអ្នកបន្តវេនសមាគមជាតិកាកបាទក្រហមខ្មែរ ដែលបានបង្កើតឡើងតាំងពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ១៩៥៥ ក្នុងគោលបំណងផ្តល់ជំនួយសង្គ្រោះ និងធ្វើជាជំនួយការអោយអាជ្ញាធរសាធារណៈ ក្នុងវិស័យមនុស្សធម៌ ។ សមាគមនេះ ត្រូវបានទទួលស្គាល់ដោយគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម (ICRC) នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ ១៩៦០ និងត្រូវបានបញ្ចូលជាសមាជិករបស់សហព័ន្ធអន្តរជាតិនៃសមាគមជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម នៅថ្ងៃទី ០៨ ខែតុលា ឆ្នាំ ១៩៦០ ។

មាត្រា ៣ .—

កាកបាទក្រហមកម្ពុជា ត្រូវធ្វើសកម្មភាពដោយត្រឹមត្រូវ ទៅតាមគោលការណ៍គ្រឹះទាំងប្រាំពីររបស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ដែលមាន ភាពមនុស្សធម៌, ភាពមិនលំអៀង, អព្យាក្រឹតភាព, ឯករាជ្យភាព, សេវាកម្មស្ម័គ្រចិត្ត, ឯកភាព និង សកលភាព ។

មាត្រា ៤ .—

កាកបាទក្រហមកម្ពុជា ត្រូវបានទទួលស្គាល់និងអនុញ្ញាតអោយផ្តល់ការជួយឧបត្ថម្ភចំពោះសេវាកម្មពេទ្យរបស់កងកំលាំងប្រដាប់អាវុធក្នុងពេលមានជំលោះប្រដាប់អាវុធ ដោយផ្អែកលើមូលដ្ឋាននៃ អនុសញ្ញាក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ដែលបានយល់ព្រមដោយ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ១៩៥៨ និងពិធីសារបន្ថែមនាថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ១៩៧៧ ។

មាត្រា ៥ .—

កាកបាទក្រហមកម្ពុជា ជានិច្ចកាលត្រូវធ្វើសកម្មភាពត្រឹមត្រូវតាមលក្ខន្តិកៈ វិធាននៃនីតិក្រម និងបទប្បញ្ញត្តិហិរញ្ញវត្ថុ ដែលបានអនុម័តដោយកាកបាទក្រហមកម្ពុជា ។

មាត្រា ៦ .—

កាកបាទក្រហមកម្ពុជា ត្រូវបានអនុញ្ញាតអោយប្រើបដិរូបកាកបាទក្រហមនៅលើផ្ទៃស ដូចមានចែងនៅក្នុងលក្ខន្តិកៈរបស់ខ្លួន និងសមស្របទៅតាមអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ពិធីសារបន្ថែមចុះថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ១៩៧៧ និងបទបញ្ជាអំពីការប្រើប្រាស់បដិរូបរបស់សមាគមជាតិ ដែលអនុម័តដោយសន្និសីទអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហមលើកទី ២០ និង វិសោធនកម្មជាបន្តបន្ទាប់មកទៀត ។

## ជំពូកទី ២
## គោលដៅ

មាត្រា ៧ .—

គោលដៅរបស់កាកបាទក្រហមកម្ពុជា គឺបង្ការនិងបន្ថយទុក្ខលំបាកវេទនា ដោយភាពមិនលំអៀង ដ៏ពិតប្រាកដ ដោយឥតប្រកាន់ពូជសាសន៍, ពណ៌សម្បុរ, ភេទ, ភាសា, ជំនឿ, សាសនា, និន្នាការនយោបាយ, ដើមកំណើតជាតិ, ឋានៈសង្គម, ធនធាន ឬស្ថានភាពឯទៀតឡើយ ។

មាត្រា ៨ .—

ដើម្បីបំពេញភារៈកិច្ច ដូចមានចែងក្នុងមាត្រា៦ នៃព្រះរាជក្រឹត្យនេះ កាកបាទក្រហមកម្ពុជា ត្រូវទទួលយកមុខងាររបស់ខ្លួន ដោយសមស្របទៅតាមលក្ខន្តិកៈ និងបទបញ្ជានៃសន្និសញ្ញាអន្តរជាតិ ដែលកម្ពុជាជាភាគីមួយ ហើយនឹងសេចក្តីសំរេចចិត្តរបស់សន្និសីទអន្តរជាតិកាកបាទក្រហម និង អឌ្ឍច័ន្ទ ក្រហម និងឯកសារផ្លូវការផ្សេងៗទៀត របស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ។

## ជំពូកទី ៣
## វិសាលភាព និង ដែនអនុវត្ត

មាត្រា ៩ .—

កាកបាទក្រហមកម្ពុជា ជាសមាគមជាតិកាកបាទក្រហមតែមួយគត់ដែលបំពេញសកម្មភាពមនុស្សធម៌ក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល ។

មាត្រា ១០ .—

កាកបាទក្រហមកម្ពុជា ជានិច្ចកាលធ្វើសកម្មភាពដោយអនុលោមតាមអនុសញ្ញាក្រុងហ្សឺណែវ និងពិធីសារបន្ថែម ច្បាប់ទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍នៃចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម និងសេចក្តីសំរេចទាំងឡាយដែលអនុម័តដោយ សន្និសីទអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម និងឯកសារផ្លូវការផ្សេងៗទៀតរបស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ។

មាត្រា ១១ .—

អាជ្ញាធរសាធារណៈ ជានិច្ចកាលត្រូវតែគោរពនូវការផ្សារភ្ជាប់យ៉ាងជិតស្និទរបស់កាកបាទក្រហមកម្ពុជា ទៅនឹងគោលការណ៍គ្រឹះរបស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ដូចមានចែងក្នុងសេចក្តីសំរេចលេខ ៥៥ I នៃមហាសន្និបាតរបស់អង្គការសហប្រជាជាតិ អនុម័តនៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ១៩៤៦ ។

មាត្រា ១២ .—

ជាសមាជិករបស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម កាកបាទក្រហមកម្ពុជា អាចទទួលយករាល់សកម្មភាពដែលខ្លួនយល់ស្រប ជាមួយនឹងកិច្ចសហប្រតិបត្តិការ និងក្នុងការសំរបសំរួលជាមួយគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម សហព័ន្ធអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ដែលហៅថាសហព័ន្ធ និងសមាគមជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហមដទៃទៀត ។

## ជំពូកទី ៤
## ភារកិច្ច និង តួនាទី

មាត្រា ១៣ .—

កាកបាទក្រហមកម្ពុជា ត្រូវធ្វើតាមភារកិច្ចរបស់ខ្លួនដែលជាសមាសភាគមួយ របស់ចលនាអន្តរជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម និងជាសមាជិកមួយរបស់សហព័ន្ធអន្តរជាតិនៃសមាគមជាតិកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហម ។

មាត្រា ១៤ .—

កាកបាទក្រហមកម្ពុជា ត្រូវមានរចនាសម្ព័ន្ធអភិបាលកិច្ច និងគ្រប់គ្រងមួយ ដូចមានចែងនិងពណ៌នាដោយលក្ខន្តិកៈរបស់ខ្លួន ។

មាត្រា ១៥ .—

កាកបាទក្រហមកម្ពុជា អាចកែសំរួលលក្ខន្តិកៈ វិធាននៃនីតិក្រម និងបទប្បញ្ញត្តិហិរញ្ញវត្ថុរបស់ខ្លួនគ្រប់ពេលវេលា ដោយធ្វើទៅតាមនីតិវិធី ដែលបានកំណត់ ។

## ជំពូកទី ៥
## ថវិកា និង ធនធាន

មាត្រា ១៦ .—

កាកបាទក្រហមកម្ពុជាគ្រប់គ្រងនិងចាត់ចែងលើធនធាន ថវិកា របស់ខ្លួន ធនធាន និងកំរៃផ្សេងៗទៀត ហើយនិងអំណោយដែលបានមកពីសកម្មភាពនានានិងបេសកកម្មរបស់ខ្លួន ។ លើសពីនេះទៅទៀត កាកបាទក្រហមកម្ពុជា អាចបង្កើតឱ្យមាននិងគ្រប់គ្រងធនធានបំរុង, ធនធានធានារ៉ាប់រង, ធនធានសង្គម ឬធនធានផ្សេងៗទៀតសំរាប់បុគ្គលិក ឬសំរាប់សកម្មភាពណាមួយរបស់ខ្លួន ។

មាត្រា ១៧ .–

នៅក្នុងព្រំដែនដែលបានកំណត់ក្នុងទិសដៅ កាកបាទក្រហមកម្ពុជា អាចទទួលយក ធ្វើជាម្ចាស់ ហើយគ្រប់គ្រងទ្រព្យសម្បត្តិ និងសហគ្រាសពាណិជ្ជកម្មផងទាំងពួង ដែលយល់ថាសមស្រប ។ កាកបាទក្រហមកម្ពុជា អាចទទួលយកទ្រព្យសម្បត្តិ ដែលត្រូវបានធ្វើជាអំណោយ ឬត្រូវបានផ្ទេរប្រគល់អោយ សំរាប់ប្រើប្រាស់ ឬសំរាប់ជាប្រយោជន៍របស់កាកបាទក្រហមកម្ពុជា ។

មាត្រា ១៨ .–

កាកបាទក្រហមកម្ពុជា អាចទទួលឬបដិសេធវិភាគទាន និងជំនួយគ្រប់ទ្រង់ទ្រាយដែលគ្មានលក្ខខណ្ឌ ពីឯកត្តបុគ្គល ពីអាជ្ញាធរសាធារណៈ និងពីអង្គភាពឯកជន ឬសាធារណៈ សមស្របតាមទិសដៅ និងមុខនាទី របស់ខ្លួន ។

កាកបាទក្រហមកម្ពុជា អាចទទួលធ្វើជាភ្នាក់ងារ ឬជាអ្នកគ្រប់គ្រងមូលនិធិ ឬទ្រព្យសម្បត្តិ ដែលម្ចាស់ទ្រព្យបានផ្តល់ការទុកចិត្តមកលើ ឬបានកំណត់ទុកអោយប្រើប្រាស់ជាពិសេស ក្នុងន័យដែលថា ការប្រើប្រាស់នោះស្ថិតនៅក្នុងវិសាលភាពទូទៅនៃទិសដៅ និងមុខនាទីរបស់ខ្លួន ។

មាត្រា ១៩ .–

ចំពោះពន្ធអាករទាំងអស់ ក្នុងនោះមានរាប់បញ្ចូលទាំងអាករបន្ថែមលើតំលៃពន្ធគយ (VAT) និងអាករនានាផង របស់កាកបាទក្រហមកម្ពុជា រួមមានធនធានហិរញ្ញវត្ថុ និងអចលនទ្រព្យ ក៏ដូចជាប្រាក់ចំណូលដែលបានមកពីការធ្វើសកម្មភាពរកចំណូល ជាបន្ទុករបស់រដ្ឋ ។

មាត្រា ២០ .–

ជំនួយបរិច្ចាគនានា ដែលឯកត្តបុគ្គល ឬអង្គភាពស្របច្បាប់ណាមួយ បានផ្តល់ជូនកាកបាទក្រហមកម្ពុជា ក្នុងនោះមានទាំងការប្រគល់កេរ្តិ៍មរតកផង ត្រូវបានលើកលែងអោយរួចផុតពីការបង់ពន្ធអាករ ។

មាត្រា ២១ .–

អាជ្ញាធរសាធារណៈ ត្រូវចេញថ្លៃចំណាយលើសកម្មភាពណាមួយដែលខ្លួនបំពេញជូនសមាគមជាតិ នៅក្នុងវិសាលភាពនៃទិសដៅ និងតួនាទីរបស់កាកបាទក្រហមកម្ពុជា ។ លក្ខខណ្ឌទាំងឡាយសំរាប់ការបំពេញសេវាកម្ម ឬសកម្មភាពទាំងនោះ ត្រូវមានចុះនៅក្នុងកិច្ចព្រមព្រៀងរវាងកាកបាទក្រហមកម្ពុជា និងអាជ្ញាធរសាធារណៈដែលពាក់ព័ន្ធ ។

មាត្រា ២២.—

កាកបាទក្រហមកម្ពុជា ជានិច្ចកាលត្រូវគោរព និងស្ថិតនៅក្រោមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិរបស់ខ្លួន ។ កាកបាទក្រហមកម្ពុជា ត្រូវមានវិធានការចាំបាច់ ដើម្បីធានាដល់ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិទាំងនេះ ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

មាត្រា ២៣.—

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៤.—

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែឧសភា ឆ្នាំ ២០០២

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

នស/រកត.០២.០៥.០០១២៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ១០០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ អាន